**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គស្នងការដ្ឋាននគរបាលជាតិ**

លេខ: ២០៤ របក

ភ្នំពេញ,ថ្ងៃទី ១៧ ខែ កក្កដា ២០០៧

# របាយការណ៍

## សង្ខេបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧

### I-សភាពការណ៍សន្តិសុខជាតិ និងកិច្ចប្រតិបត្តិការ

#### ក-សភាពការណ៍

កងកម្លាំងនគរបាលជាតិបានសហការជាមួយគ្រប់ ផ្នែកពាក់ព័ន្ធ រក្សាបានស្ថេរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បង្ការទប់ស្កាត់បាននូវអំពើភេរវកម្ម ឧក្រិដ្ឋកម្ម ឆ្លងដែន ការបង្កសម្លេងផ្ទុះនានា ការពារជូនប្រកបដោយសុវត្ថិភាពទាំងស្រុងព្រឹត្តិការណ៍នយោបាយដែលកើតមានឡើង និងសេចក្តីសុខក្សេមក្សាន្ត ជូនប្រជាពលរដ្ឋ កត់សម្គាល់ ដូចខាងក្រោម:

-ការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ទាំងមូលក្នុង និងក្រោយការបោះឆ្នោតប្រព្រឹត្តទៅបានល្អប្រសើរ ទទួលបានការកោតសរសើរពីអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ។

-ការតាំងពិពណ៌វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូរ (កម្ពុជា-កូរ៉េ) រយៈពេល ៥០ថ្ងៃ ។

-មិទ្ទិញរំលឹកខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិលើកទី៦២ (ថ្ងៃទី ១៥-៥-១៩៤៥ ដល់ ថ្ងៃទី ១៥-៥-២០០៧) ប្រកបដោយជោគជ័យ ។

ក្រៅពីនេះយើងរក្សាការពារបានទាំងស្រុងគោលដៅនយោបាយ ការទូត វប្បធម៌ សេដ្ឋកិច្ច និងការពារប្រកបដោយសុវត្ថិភាពព្រះរាជបេសកកម្មរបស់ព្រះមហាក្សត្រ ថ្នាក់ដឹកនាំជាន់ខ្ពស់ និង ឥស្សរជនសំខាន់ៗ ព្រមទាំងទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ ថ្នាក់ដឹកនាំរដ្ឋ នៃបណ្តាប្រទេសជាមិត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

#### ខ-លទ្ធផលប្រតិបត្តិការ

#### ១-ការងារអន្តោប្រវេសន៍

-បានត្រួតពិនិត្យ និងសម្រួលដំណើរចេញ-ចូលដល់ភ្ញៀវបរទេសមាន ចូលជាលក្ខណៈអន្តរជាតិចំនួន ៩៩៤.៥៩៤នាក់ និងចូលជាលក្ខណៈតំបន់ចំនួន ៤៣.៥៩៦នាក់ ។

-ចំនួនភ្ញៀវបរទេស ដែលមកធ្វើទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជាក្នុងឆមាសទី១ នេះមានចំនួន ៨៥៦.៤១៩នាក់ ក្នុងនោះនាំមុខគេនៅតែជនជាតិ កូរ៉េ ជប៉ុន អាមេរិក ចិន វៀតណាម ។ល។ យើងបានរកឃើញ

ជនបរទេសល្មើសច្បាប់ចំនួន ២០៥នាក់ (២៩ សញ្ជាតិ) ពាក់ព័ន្ធការជួញដូរគ្រឿងញៀន (៦ករណី ឃាត់ខ្លួន ៩នាក់) និងប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ និងមិនគ្រប់លក្ខណៈសម្បត្តិអោយចូលព្រះរាជាណាចក្រកម្ពុជា ។

-បានផ្តល់ទិដ្ឋាការនៅតាមច្រកទ្វារអន្តរជាតិនានាបានចំនួន ២៦១.៣១៤នាក់ (ទេសចរណ៍ ២៤០.៧៨៣នាក់ ពាណិជ្ជករ ៥.៨៩៨នាក់ និងមិនបង់ប្រាក់ ១៤.៦៣៣នាក់) និងផ្តល់ទិដ្ឋាការចេញចំនួន ១១៣នាក់ មាន ៤៥ សញ្ជាតិ ។

-បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះត្រួតពិនិត្យប័ណ្ណការងារជនបរទេសតាមរោងចក្រ សហគ្រាស បានចំនួន ៣៦០កន្លែង រកឃើញជនបរទេសចំនួន ២០៨នាក់ ក្នុងចំណោមពលករបរទេស ២.១៣៥នាក់ កំពុងបម្រើការងារដោយគ្មានប័ណ្ណការងារ (យើងបានណែនាំអោយទៅសុំប័ណ្ណការងារអោយបានត្រឹមត្រូវតាមផ្លូវច្បាប់ ។

**២-ការងាររដ្ឋបាលអន្តរជាតិ**

-បានទទួលលិខិត (I.24-7) ចូលពីបរទេស ១៤៧ច្បាប់ និងបញ្ជូនចេញទៅបរទេសវិញ ៣២ច្បាប់ ។

**៣-ការងាររដ្ឋបាលទេសចរណ៍**

-បានទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ជនបរទេសចំនួន ៣៥៣ករណី ក្នុងនោះបានចេញលិខិតបញ្ជាក់ ២០៦ករណី សហការស្រាវជ្រាវ ១១២ករណី ឃាត់ខ្លួន ១ករណី ដោះស្រាយ ៥ករណី អប់រំណែនាំ ៦ករណី និងរកឃើញប្រគល់ជូនភ្ញៀវវិញ ២៣ករណី ។

**II-<u>ការងារព្រហ្មទណ្ឌ និងកិច្ចប្រតិបត្តិការ</u>**

**១-ការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌ**

-បង្ក្រាបបាន ១.៨២៥ករណី ស្មើនឹង ៨១.៧៦% នៃចំនួនរឿងហេតុកើតឡើង ឃាត់ខ្លួនជនល្មើស ២.៥១១នាក់ ក្នុងនោះមានបទល្មើសឧក្រិដ្ឋ ៥៨៩ករណី ឃាត់ខ្លួន ៨៤៥នាក់ បទល្មើសមជ្ឈិម ១.២៣៦ករណី ឃាត់ខ្លួន ១.៦៦៦នាក់ រឹបអូសវត្ថុតាងរួមមាន អាវុធខ្លី ៣១ដើម អាវុធវែង ២៣ដើម ម៉ូតូ ១៤៤គ្រឿង រថយន្ត ១០គ្រឿង និងសម្ភារៈមាសប្រាក់មួយចំនួន ។

-បានកសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន ១.៦៣៤ករណី ជនល្មើស ២.២១៥នាក់ ក្នុងនោះបទល្មើសឧក្រិដ្ឋ ៥៨៦ករណី ជនល្មើស ៨៤២នាក់ និងបទល្មើសមជ្ឈិម ១.០៤៨ករណី ជនល្មើស ១.៣៧៣នាក់ ព្រមទាំងវត្ថុតាង ។

-បានធ្វើការឃាត់ខ្លួនក្រុមក្មេងស្ទាវពាលាអាវ៉ាសែ ចំនួន ៨៩១នាក់ ក្នុងនោះធ្វើការអប់រំណែនាំ ៨៥៥នាក់ និងបញ្ជូនទៅតុលាការ ៣៦នាក់ ។

**២-ការងារប្រឆាំងការជួញដូរផ្លូវភេទ**

បង្ក្រាបបាន ១៧៦ករណី ឃាត់ខ្លួនជនល្មើសជាមេក្លោងចំនួន ២០៤នាក់ (បញ្ជូនទៅតុលាការ) និងសង្គ្រោះនារីរងគ្រោះបាន ២៤៧នាក់ ។

**៣-ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**

បង្ក្រាបករណីជួញដូរគ្រឿងញៀនសរុបបានចំនួន ៧២ករណី ឃាត់ខ្លួន ១៣៤នាក់ បាញ់ស្លាប់ ១នាក់ របួស ១នាក់ (ស្រី៣១នាក់) ក្នុងនោះជនជាតិខ្មែរ ១០២នាក់ វៀតណាម ១៦នាក់ ថៃ ៤នាក់ ម៉ាឡេស៊ី ៣នាក់ និងចិន

៣នាក់ ។វត្ថុតាងគ្រឿងញៀនដកហូតរួមមាន ម្សៅសារធាតុគីមីផ្សំគ្រឿងញៀន៥.៧៧០គ.ក្រ ម៉ាស៊ីនឧបករណ៍គ្រឿងសម្ភារៈសម្រាប់ផលិតគ្រឿងញៀនជាច្រើនមុខ ថ្នាំញៀនមេតំហ្វេតាមីន ៩៧.៨៤៧គ្រាប់ ហេរ៉ូអ៊ីន ១.៩៣២ក្រាម ៥0 ម្សៅ ICE ៧៣៧ក្រាម ៦៧កូនកញ្ចប់តូច ពុម្ពផលិតគ្រឿងញៀនកែច្នៃ ៦ កញ្ឆាក្រៀម ១០គ.ក្រ ប្រេងម្រះព្រៅ ១.២៦០លីត្រ អាវុធខ្លី ៥ដើម អាវុធវែង ១ដើម រថយន្ត ៧គ្រឿង ម៉ូតូ ៧គ្រឿង និងឧបករណ៍សម្ភារៈចាក់ជក់ជាច្រើនទៀត ។ ករណីទាំងអស់នេះបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

## III-<u>សភាពការណ៍សណ្តាប់ធ្នាប់សាធារណៈ និងកិច្ចប្រតិបត្តិការ</u>

### ក-សភាពការណ៍

**១-សភាពការបទឧក្រិដ្ឋ-ក្បួនកម្ម** ៖ កើតឡើងចំនួន ២៨លើក

**២-សភាពការណ៍គ្រោះថ្នាក់សង្គម** ៖ កើតឡើងចំនួន ៣.៥៥៥លើក (កើន ៧៥១លើក) រួមមាន គ្រោះថ្នាក់ចរាចរ ២.៥៧៦លើក លើ ២.០៣៦លើក បណ្តាលឱ្យស្លាប់ ៦២៥នាក់ របួស ៤.៥៨៥នាក់ មូលហេតុ នៃការគ្រោះថ្នាក់នេះ អាស្រ័យដោយកត្តាមួយចំនួនដូចជា កត្តាមនុស្ស យានយន្តមានការកើនឡើងជាលំដាប់ ផ្លូវថ្នល់តូចចង្អៀត... ជាពិសេសការបើកបរមិនគោរពច្បាប់ចរាចរ ។ គ្រោះថ្នាក់ដោយអាវុធជាតិផ្ទុះ ៥៧លើក អគ្គីភ័យ ២៦២លើក ខ្យល់ព្យុះ ៥៣លើក អត្តឃាត ២២៩លើក និងគ្រោះថ្នាក់ផ្សេងៗ ៣៨៧លើក ។ ករណីទាំងអស់នេះបណ្តាលឱ្យស្លាប់ ១.៣០៦នាក់ របួស ៤.៨៤៦នាក់ ឆេះផ្ទះ ១.២៥៧ខ្នង តូបលក់ដូរ ១.០៦០តូប ឆេះស្រូវ ៥៤ហិតា រលំផ្ទះ ៣៣៨ខ្នង និងសាលារៀន ៥ខ្នង ។

### ខ-កិច្ចប្រតិបត្តិការ

**១-ការងារការពារ**

បានសហការការពារប្រកបដោយសុវត្ថិភាពថ្វាយព្រះមហាក្សត្រ រាជរដ្ឋាភិបាល គណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ កិច្ចប្រជុំសន្និបាត និងតាមបណ្តាកម្មវិធីផ្សេងៗ សរុបបានចំនួន ៨៧៣លើក ក្នុងនោះការពារគណៈប្រតិភូអន្តរជាតិបានចំនួន ៥៣លើក ។

**២-ការងារចរាចរ**

-បានព្រាងអនុក្រឹត្យស្តីពីការបង្កើតគណកម្មការចំរុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសចរាចរ អនុក្រឹត្យស្តីពីការបង្កើតគណកម្មការចំរុះត្រួតពិនិត្យសាលារៀនបើកបរ និងយានដ្ឋានជួសជុលរថយន្ត ។

-បានព្រាងអនុក្រឹត្យស្តីពីសណ្តាប់ធ្នាប់សាធារណៈជាថ្មី ។

-បានបើកវគ្គរៀនសូត្រច្បាប់ចរាចរថ្មីដល់នាយនគរបាលនៅក្រសួង និងខេត្ត-ក្រុង ចប់សព្វគ្រប់តាមផែនការកំណត់ និងកំពុងត្រៀមចាត់តាំងអនុវត្តច្បាប់ថ្មីនៅក្នុងឆមាសទី២ ខាងមុខនេះ ។

**៣-ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ**

ធ្វើការចុះបញ្ជីគ្រប់គ្រងអាវុធជាតិផ្ទុះ តាមអនុក្រឹត្យលេខ ៣៨ អនក្រ បាន ៖

-ផ្តល់ប័ណ្ណប្រើប្រាស់អាវុធចំនួន ៩២៨ប័ណ្ណ (ខ្លី ១៣៥ដើម និងវែង ៧៩៣ដើម) ។

-ប្តូរប័ណ្ណប្រើប្រាស់អាវុធចំនួន ៧២៧ប័ណ្ណ (ខ្លី ៥២៩ដើម និងវែង ១៩៨ដើម) ។

សរុបពីមុនមកដល់បច្ចុប្បន្ន អាវុធផ្តល់ប័ណ្ណប្រើប្រាស់ចំនួន ១៨.១៩៥ដើម ក្នុងនោះអាវុធខ្លីចំនួន ៧.៩២៥ដើម (បុគ្គល ១.៤០៤ដើម) និងអាវុធវែង ចំនួន ១០.២៧០ដើម ។

**៤-ការងារគ្រប់គ្រងស្ថិតិពលរដ្ឋ និងលិខិតឆ្លងដែន**

-ផ្តល់សៀវភៅស្នាក់នៅបានចំនួន ២.៣៣៨.៧០០គ្រួសារ

-ផ្តល់សៀវភៅគ្រួសារ បានចំនួន ២.២០១.៩៨១គ្រួសារ

-ធ្វើរបាយការណ៍ស្ថិតិប្រជាពលរដ្ឋ អាយុ ១៧ឆ្នាំឡើងសរុបចំនួន ៧.៩៤៩.៧៥៩នាក់ ជូនរដ្ឋសភាជាតិ សម្រាប់គំរោងបោះឆ្នោតតំណាងរាស្ត្រអណត្តិទី ៤ ឆ្នាំ ២០០៨ ។

-ផ្តល់សៀវភៅឆ្លងដែនជូនប្រជាពលរដ្ឋបានចំនួន ១៧.៩៩៦នាក់ ។

## IV-ការងារការពារព្រំដែន

យើងបានធ្វើការដោះស្រាយជាមួយភាគីមិត្តបាន ៦លើក និង ៤លើកទៀតកំពុងបន្តដោះស្រាយ ។

## V-ការងារបុគ្គលិក និងបណ្តុះបណ្តាល

-កាត់បន្ថយក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ អសកម្ម ល្មើសវិន័យ លាឈប់បម្រើការងារ ចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ផ្ទេរនគរបាលពលី ពិការ មរណៈ បានចំនួន ៣៣២នាក់ (បន្ថយចេញពីក្របខ័ណ្ឌ ៧២នាក់ ផ្ទេរទៅក្រសួងសង្គមកិច្ច ២៦០នាក់) ។

-បញ្ចូលក្របខ័ណ្ឌជ្រើសរើសថ្មីមានចំនួន ៤.១០១នាក់ ដូចនេះក្របខ័ណ្ឌមន្ត្រីនគរបាលជាតិបច្ចុប្បន្ន នៅទូទាំងប្រទេស គិតពីខែមករា ដល់ខែ មេសា ឆ្នាំ២០០៧ សរុបចំនួន ៥៤.៥៨៧នាក់ (ស្រី ២.២១២នាក់) រួមមាន ៖

+នាយកដ្ឋាន-អង្គភាព ចំនួន ១៣.១៣២នាក់ (ស្រី ៨១៧នាក់)

+ខេត្ត-ក្រុង ចំនួន ៤១.៤៥៥នាក់ (ស្រី ១.៣៩៥នាក់)

## VI-ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧

១-ប្រមូលផ្តុំក្តាប់សភាពការណ៍ ព័ត៌មានពាក់ព័ន្ធដល់សន្តិសុខជាតិទាំងក្នុង និងក្រៅប្រទេស ធ្វើការវិភាគវាយតម្លៃអោយបានគ្រប់ជ្រុងជ្រោយ ព័ត៌មានដែលក្តាប់បានដើម្បីដាក់ចេញទិសដៅតស៊ូអោយបានសម្រេចតាមដំណាក់កាលនីមួយៗ ក្នុងនោះត្រូវ ៖

-ក្តាប់បានទាន់ពេល ឧបាយកល ផែនការ សកម្មភាពរបស់ក្រុមអមិត្ត ដែលប៉ុនប៉ងបង្កភាពច្របូកច្របល់ខាងនយោបាយតាមគ្រប់រូបភាព ប៉ះពាល់ដល់សុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម ។

-ក្តាប់បានរាល់ការប្រមូលផ្តុំធ្វើបាតុកម្ម កូដកម្មរបស់កម្មកររោងចក្រ និងការប្រមូលផ្តុំតវ៉ាទាមទាររបស់ប្រជាពលរដ្ឋ ក្នុងនោះយកចិត្តទុកដាក់ក្តាប់ពីមូលហេតុ ខ្លឹមសារ និងគោលបំណងសំណូមពរ នៃការតវ៉ាទាមទារដើម្បីដាក់ចេញវិធានការដោះស្រាយបានសមស្រប និងបញ្ចៀសបាននូវអំពើហឹង្សាដែលកើតឡើងជាយថាហេតុ ។

-បង្កើនកិច្ចសហការប្រតិបត្តិការជាមួយសហគមន៍ជាតិ-អន្តរជាតិ ក្នុងការទប់ស្កាត់បង្ក្រាបអំពើភេរវកម្ម និងឧក្រិដ្ឋជនឆ្លងដែន ។

២-ពង្រឹងកិច្ចការពារបណ្តាគោលដៅសំខាន់ៗ នយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ និងការពារប្រកបដោយសុវត្ថិភាពដាច់ខាត ព្រះសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពប្រមុខរាជរដ្ឋាភិបាល ឥស្សរជនជាន់ខ្ពស់ ក្នុងការបំពេញបេសកម្ម ឬចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងបណ្តាគណៈប្រតិភូជាមិត្ត ដែលអញ្ជើញមកធ្វើទស្សនកិច្ចជាផ្លូវការនៅកម្ពុជា ។

៣-ប្រមូលផ្តុំវាយតម្លៃសភាពការបទល្មើសព្រហ្មទណ្ឌទូទាំងប្រទេស ដើម្បីដាក់ចេញវិធានការជំនាញ និងវិធានការចាំបាច់ទាំងឡាយ សំដៅបង្កើនប្រសិទ្ធភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ជា

ពិសេសអំពើប្លន់ប្រដាប់អាវុធ អំពីមនុស្សឃាត ការរំលោភផ្លូវភេទ អំពើជួញដូរស្ត្រី និងកុមារ ព្រមទាំងសកម្មភាពល្មើសច្បាប់ផ្សេងៗ ដែលបង្កឱ្យមានការភ័យខ្លាចក្នុងសង្គម ។

-ចាត់វិធានការបំបាត់ប្រសិទ្ធភាពក្រុមក្មេងស្ទាវពាលាអាវ៉ាសែ ដែលធ្វើសកម្មភាពបង្កការបាត់សណ្តាប់ធ្នាប់ក្នុងសង្គម និងបង្កើនការបោសសំអាតបណ្តាបាតុភាពអសកម្មនានា ដែលជាចំណុចចាប់ផ្តើមនៃការកកើតឡើងនូវបទល្មើស ។

៤-ជំរុញខ្លាំងក្លា ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបង្កើនការតាមដាន ក្តាប់ និងគ្រប់គ្រងមុខសញ្ញាដែលសង្ស័យពាក់ព័ន្ធការជួញដូរ ប្រើប្រាស់គ្រឿងញៀន បង្កើនកិច្ចសហប្រតិបត្តិការជាមួយខេត្តជាប់ព្រំដែនវៀតណាម ឡាវ ក្នុងការត្រួតពិនិត្យទប់ស្កាត់ការដឹកជញ្ជូនគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងធ្វើការផ្សព្វផ្សាយអប់រំដល់មន្ត្រីរាជការ ប្រជាពលរដ្ឋ និងសិស្សានុសិស្ស តាមគ្រឹះស្ថានសិក្សានានាទូទាំងប្រទេសចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ពិនិត្យឡើងវិញការអនុវត្តន៍ផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ជំរុញធ្វើការស្រាវជ្រាវជាមូលដ្ឋានអោយបានខ្លាំងក្លា ក្តាប់និងគ្រប់គ្រងមុខសញ្ញា ជាពិសេសមុខសញ្ញាចេញពីពន្ធនាគារ ។ ទន្ទឹមនេះចាត់តាំងបូកសរុប ត្រួតពិនិត្យលទ្ធផលការអនុវត្តន៍ផែនការ ប្រៀបសមរភូមិជំហានទី២ ដើម្បីបើកកិច្ចប្រជុំប្រចាំឆមាសទី១ និងផ្សព្វផ្សាយទិសដៅអនុវត្តបន្ត ។

-បន្តចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង រៀបចំបណ្តាលិខិតបទដ្ឋាននានា ដើម្បីបំពេញបន្ថែមអោយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនធានាបានប្រសិទ្ធភាពការងារដល់មន្ត្រីអនុវត្តច្បាប់ ។

៥-ចាត់តាំងការអនុវត្តអនុក្រឹត្យស្តីពីការផ្តល់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ជូនប្រជាពលរដ្ឋពីអាយុ ១៥ឆ្នាំជាពិសេសធ្វើយ៉ាងណាអោយការផ្តល់នេះបំរើបានគ្រប់គ្រាន់ សំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៤ ។

៦-ពិនិត្យលទ្ធភាព សមត្ថភាពមន្ត្រីនគរបាលចរាចរ និងចាត់តាំងដំណើរការអនុវត្តច្បាប់ចរាចរផ្លូវគោកថ្មីអោយមានប្រសិទ្ធភាពនាឆមាសទី២ ឆ្នាំ២០០៧ ខាងមុខនេះ ។

៧-សហការជាមួយក្រសួងសាធារណការ ព្រាងច្បាប់នាវាចរណ៍ និងបន្តព្រាងអនុក្រឹត្យស្តីពីសណ្តាប់ធ្នាប់សាធារណជាថ្មី ។

៨-សហការត្រួតពិនិត្យលើការចុះបញ្ជីគ្រប់គ្រង អាជីវកម្ម សិប្បកម្មកែច្នៃ ដែលមានការពាក់ព័ន្ធជាតិផ្ទុះគ្រឿងផ្ទុះ ។

៩-បង្កើនកិច្ចការពារសន្តិសុខ និងរក្សាសុវត្ថិភាពសណ្តាប់ធ្នាប់ ជូនព្រះមហាក្សត្រ ប្រមុខរាជរដ្ឋាភិបាលឥស្សរជនជាន់ខ្ពស់ជាតិ អន្តរជាតិ រាល់ការបំពេញបេសកកម្មរបស់គណៈប្រតិភូជាតិ អន្តរជាតិ និងពិធីបុណ្យនានាប្រកបដោយសុវត្ថិភាព ។

១០-ពង្រឹងកិច្ចរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ តាមបណ្តោយព្រំដែន និងបង្កើនប្រសិទ្ធភាពអនុវត្តផែនការសហប្រតិបត្តិការជាមួយប្រទេសជិតខាង សំដៅទប់ស្កាត់រាល់បទល្មើសគ្រប់ប្រភេទដើម្បីរក្សាបាននូវសេចក្តីសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រំដែន និងធានាបានខ្សែបន្ទាត់ ព្រំដែនសន្តិភាព និងអភិវឌ្ឍន៍ ។

-រៀបចំកែសម្រួលតួនាទី ភារកិច្ច សិទ្ធិរបស់នាយកដ្ឋាន វរៈសេនាតូច និងប៉ុស្តិ៍ការពារព្រំដែនតាមការងារអនុវត្តសព្វថ្ងៃអោយបានសមស្របត្រឹមត្រូវ និងប្រសិទ្ធភាព ។

-បន្តសហការជាមួយអនុគណៈកម្មការបច្ចេកទេសព្រំដែនកម្ពុជា-វៀតណាម ដើម្បីដំណើរការបោះបង្គោលព្រំដែន នៃប្រទេសទាំងពីរ ។ ទន្ទឹមនោះសហការជាមួយអនុគណៈកម្មការបច្ចេកទេសព្រំដែនកម្ពុជា-ថៃ រុករកបង្គោលសីមាចាស់តាមព្រំដែនប្រទេសទាំងពីរ ។

១១-បន្តរៀបចំតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ដែលមានលក្ខណៈសមស្របតាមការកំណត់ នៃលក្ខន្តិកៈ និងរៀបចំគោលការណ៍ស្នើសុំគ្រឿងឥស្សរិយស មេដាយគ្រប់ប្រភេទ ប័ណ្ណសរសើរ លិខិតសរសើរជូនមន្ត្រីនគរបាលជាតិ ដែលមានស្នាដៃក្នុងការបំពេញភារកិច្ច ។

-ពិនិត្យរៀបចំតួនាទី ភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានដែលពុំទាន់បានរៀបចំ និងបណ្តានាយកដ្ឋានដែលទើបកើតថ្មី ។

**អគ្គស្នងការនគរបាលជាតិ**

<u>គោរពជូន</u>

-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-អគ្គលេខាធិការដ្ឋាន (ដើម្បីជូនជ្រាប)

-ឯកសារ-កាលប្បវត្តិ